# មិនថាប្អូនគឺជានរណានោះទេ

ដោយ លីនដា ដាវីស
ផ្អែកទៅលើដំណើររឿងពិត

*អែនឌី បានគិតថា « អូ៎ អត់ទេ ។ តើមានអ្វីនឹងកើតឡើង ប្រសិនបើខ្ញុំពុំបានផ្សារភ្ជាប់នឹងគ្រួសារខ្ញុំនោះ ? »*



« *ខ្ញុំជាកូនរបស់ព្រះ ហើយទ្រង់បានចាត់ខ្ញុំមក* » ( សៀវភៅចម្រៀងកុមារ *ទំព័រ ២* ) ។

អែនឌី បានគិតនៅពេលនាងមើលកញ្ចក់ « ខ្ញុំស្អាតហើយ » ។ នាងពាក់រូបពណ៌ក្រហមដែលនាងពេញចិត្ត ។ នាងចង់ឲ្យខ្លួននាងមើលទៅស្អាតជានិច្ចនៅថ្ងៃអាទិត្យ ។ នាងបានរត់ចុះទៅជាន់ក្រោមញ៉ាំអាហារពេលព្រឹក ។

អែនឌី បានញ៉ាំនំប៉ុងមួយដុំចុងក្រោយរបស់នាង នៅពេលឡានរបស់គ្រួសារ រីឌើរ ស៊ីផ្លេរនៅលើផ្លូវ ។ « ជំរាបលា ម៉ាក់ ! ជំរាបលា ប៉ា ! » អែនឌីបាននិយាយ ថើបពួកគាត់ នៅពេលនាងរត់ចេញទៅក្រៅ ។

ទោះបីជា ម៉ាក់ និង ប៉ាពុំមែនជាសមាជិកសាសនាចក្រក្តី ពួកគាត់បានលើកទឹកចិត្តអែនឌីឲ្យទៅព្រះវិហាររាល់សប្តាហ៍ ។ គ្រួសារ រីឌើរបានដឹកនាងស្ទើរតែរាល់ថ្ងៃអាទិត្យ តាំងពីនាងបានជ្រមុជទឹក និង បញ្ជាក់ហើយមក ។ អែនឌី ចូលចិត្តរបៀបដែលពួកគេធ្វើឲ្យនាងមានអារម្មណ៍ថាគេស្វាគមន៍ និង ស្រឡាញ់នាង ។

បន្ទាប់ពីការប្រជុំសាក្រាម៉ង់ វាដល់ម៉ោងថ្នាក់កុមារ ។ អែនឌី ចូលចិត្តនៅក្នុងថ្នាក់ ក្លាហានរបស់បងប្រុស និង បងស្រី ឡុងណាស់ ។ ពួកគាត់ចិត្តល្អ ហើយពួកគាត់តែងតែបង្រៀនមេរៀនល្អបំផុត ។

បងស្រី ឡុង និយាយថា « ថ្ងៃនេះយើងនឹងនិយាយអំពីព្រះវិហារបរិសុទ្ធ ។ តើយើងស្គាល់អ្វីខ្លះអំពីព្រះវិហារបរិសុទ្ធ ? »

អែនឌីបានដឹងចម្លើយមួយ ៖ « យើងអាចធ្វើបុណ្យជ្រមុជទឹកនៅក្នុងព្រះវិហារបរិសុទ្ធ » ។ នាងមានក្តីរំភើបអំពីរឿងនោះ ដោយសាររាល់ឆ្នាំយុវនារីនៅក្នុងវួដរបស់នាង បានធ្វើដំណើរទៅព្រះវិហារបរិសុទ្ធដើម្បីធ្វើបុណ្យជ្រមុជទឹក ។ មិនយូរប៉ុន្មានអែនឌី អាចទៅទីនោះផងដែរ !

« អស្ចារ្យណាស់ អែនឌី ។ តើយើងដឹងអ្វីផ្សេងទៀត ? »

អាលីសុន មិត្តភក្តិរបស់អែនឌីបាននិយាយថា « អ្នកអាចរៀបការនៅក្នុងព្រះវិហារបរិសុទ្ធ » ។

បងស្រី ឡុង និយាយថា « ល្អណាស់ ។ តើមានអ្វីផ្សេងទៀតទេ ? »

អាលីសុន បានបន្ថែមថា « ក្រុមគ្រួសារអាចនៅជាមួយគ្នាជានិរន្តរ៍ នៅពេលយើងផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ » ។

អែនឌីបានគិតថា « ប៉ុន្តែគ្រួសារខ្ញុំអត់បានផ្សារភ្ជាប់ផងហ្នឹង ។ ម៉ាក់ និង ប៉ាពុំបានផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធទេ ! » ភ្លាមនោះទឹកមុខនាងឡើងក្រហម ហើយនាងបានចាប់ផ្តើមយំ ។

បងស្រី ឡុងបានសួរ « អែនឌី តើប្អូនកើតអី ? »

អែនឌី បានដកដង្ហើមធំ ដោយព្យាយាមមិនយំ ។ ប៉ុន្តែនាងមានអារម្មណ៍ថា បេះដូងរបស់នាងលោតខុសចង្វាក់រហូតដល់ចប់ម៉ោងរៀន ។

រូបគំនូរដោយ ប្រាន ធៀ

ពេលចប់ថ្នាក់ បងស្រី ឡុង បានអង្គុយក្បែរអែនឌី ហើយដាក់ដៃលើស្មានាង ។ គាត់បានសួរថា « តើប្អូនមានរឿងអ្វី ? »

អែនឌី និយាយថា « ខ្ញុំមិនអាចរស់នៅជាមួយម៉ាក់ និង ប៉ារបស់ខ្ញុំជានិរន្តរ៍បានទេ ។ ពួកគាត់ពុំបានរៀបការនៅក្នុងព្រះវិហារបរិសុទ្ធទេ ។ តើខ្ញុំនឹងក្លាយជាកម្មសិទ្ធិរបស់នរណាបន្ទាប់ពីខ្ញុំស្លាប់ទៅ ? តើព្រះវរបិតាសួគ៌នៅតែស្រឡាញ់ខ្ញុំឬទេ ទោះបីជាឪពុកម្តាយខ្ញុំមិនមែនជាសមាជិកនោះ ? »

បងស្រី ឡុង បានមើលចំកែវភ្នែករបស់អែនឌី ។ « មិនថាប្អូនគឺជានរណា ហើយមិនថាគ្រួសាររបស់ប្អូនបានទៅព្រះវិហារបរិសុទ្ធឬអត់នោះទេ ប្អូននៅតែជាផ្នែកមួយនៃគ្រួសាររបស់ព្រះវរបិតាសួគ៌ ។ ប្អូនអាចនៅជិតទ្រង់ ហើយធ្វើជាគំរូដល់អ្នកដទៃទៀត ។ ទ្រង់នឹងស្រឡាញ់ ណែនាំ ហើយការពារប្អូនជានិច្ច មិនថាមានរឿងអ្វីកើតឡើងឡើយ ។ ទ្រង់សព្វព្រះទ័យប្រទានពរដល់ប្អូន និង គ្រួសាររបស់ប្អូន ។ អែនឌី ប្អូនជាកូនរបស់ព្រះ » ។

បន្ទាប់ពីនោះ អែនឌី ហាក់បីដូចជាមានចិត្តរំភើបហើយបេះដូងនាងឈប់លោតខុសចង្វាក់ទៀតហើយ ។ ឥឡូវនាងមានអារម្មណ៍កក់ក្តៅក្នុងចិត្តវិញហើយ ។ នាងបានដឹងថាអ្វីដែលគ្រូបង្រៀនរបស់នាងបាននិយាយគឺជាការពិត ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ យូថាហ៍ ស.រ.អា. ។*



## តើអ្នកអាចធ្វើអ្វីខ្លះ ?

តើអ្នកអាចធ្វើអ្វីខ្លះ ប្រសិនបើឪពុកម្តាយរបស់អ្នក ឬ នរណាម្នាក់នៅក្នុងក្រុមគ្រួសារអ្នក ពុំចង់ធ្វើជាសមាជិកសាសនាចក្រនោះ ?

- សូមចាំថា ពួកគេមានសេរីភាពជ្រើសរើស ហើយថាព្រះវរបិតាសួគ៌ស្រឡាញ់ពួកគេ ។
- សូមឲ្យពួកគេដឹងថា អ្នកស្រឡាញ់ពួកគេ ។
- សូមធ្វើជាគំរូល្អដល់ពួកគេតាមរយៈការរស់នៅតាមដំណឹងល្អ ។
- សូមចងចាំពីរឿងល្អៗអំពីពួកគេ ។
- សូមអធិស្ឋានថាព្រះវរបិតាសួគ៌នឹងជួយពួកគេឲ្យទទួលអារម្មណ៍នៃសេចក្តីស្រឡាញ់របស់ទ្រង់ ហើយដឹកនាំពួកគេទៅសាសនាចក្រ ។